# ការព្យាបាលលើលទ្ធផលដែលធ្វើឱ្យវិនាសដោយការរំលោភបំពាន

អែលឌើរ រីឆាដ ជេ ស្កត
នៃកុម្មនៃពួកសាវក 12 នាក់

*អំណាចនៃការព្យាបាលគឺមានជាប់ជាមួយនឹងដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។*

ខ្ញុំសូមថ្លែងនូវសាក្សីដ៏ឧឡារិតថាតើខ្ញុំស្រឡាញ់ព្យាការី អ្នកមើលឆុត និងជាអ្នកទទួលវិវរណៈថ្មីរបស់យើង ប៉ុណ្ណា គឺប្រធាន ថូម៉ាស អេស ម៉នសុន---ថាតើខ្ញុំទុកចិត្តចំពោះលោកប៉ុណ្ណា ហើយមានឆន្ទៈដើម្បីធ្វើអ្វីក៏ដោយដែលលោកសូមឱ្យខ្ញុំធ្វើ ។

បញ្ហាខ្លះគឺងាយដឹងណាស់ ហើយមានប្រពលភាពផ្ទាល់ខ្លួន និងអាចធ្វើឱ្យដឹងខ្លួន នូវអារម្មណ៍រំខានបែបដែលថាពួកគេបានលើកឡើងយ៉ាងឧឡារិកជាសាធារណៈ ។ ប៉ុន្តែ បើបាននិយាយដោយទន់ភ្លន់ និងដោយក្តីស្រឡាញ់នៅក្នុងពន្លឺនៃសេចក្តីពិត ការពិភាក្សាពីបញ្ហាទាំងនេះនាំមកនូវការយល់ដឹងដ៏មហិមាជាងមុន អំពីឈឺចាប់ពរជ័យនៃការព្យាបាល ហើយថែមទាំងជៀសវាងនូវសោដនាកម្មនៅពេលអនាគតទៀតផង ។

វាគឺជាបំណងប្រាថ្នាដ៏ថ្លៃថ្លាក្នុងការចង្អុលបង្ហាញនូវផ្លូវ ដើម្បីជួយធ្វើឱ្យធូរស្រាលនូវអ្វីដែលខ្ញុំនិយាយទៅកាន់អ្នក ជាអ្នកដែលទទួលរងនូវលទ្ធផលដែលធ្វើឱ្យវិនាសមនៈសិកា ពាក្យសំដី ខាងរូបកាយ ហើយជាពិសេសការរំលោភបំពានខាងផ្លូវភេទ ។ ខ្ញុំក៏សូមនិយាយផងដែរទៅកាន់អ្នកដែលបានប្រព្រឹត្តអំពើទាំងនេះ ។ ខ្ញុំនឹងផ្តោតយកចិត្តទុកដាក់ទៅលើការរំលោភបំពានខាងផ្លូវភេទ ទោះបីជាពាក្យប្រឹក្សាដែលបានផ្តល់ឱ្យ អាចជួយដល់ជនដែលរងអំពើរំលោភបំពាននៃការធ្វើបាបដទៃទៃផ្សេងទៀតក្តី ។ បំណងរបស់ខ្ញុំគឺត្រូវធ្វើជាកញ្ចក់ ដើម្បីឱ្យពន្លឺនៃការព្យាបាលដ៏ទេវភាព អាចបំភ្លឺដល់ពពកនៃសេចក្តីងងឹតនៃការឈឺចាប់ ដែលបណ្តាលមកពីសកម្មភាពមិនសុចរិតរបស់អ្នកដទៃទៀត ។ ខ្ញុំសូមធ្វើជាអ្នកជួយដើម្បីទំនាក់ទំនងឱ្យយល់បាន ដើម្បីផ្តល់ជំនួយ និងមិនធ្វើឱ្យស្មុគស្មាញនូវជីវិតខូចខាតនៅពេលខាង មុខទៀត ។ ដូចគ្នានោះផងដែរថា ការយល់ដឹងឱ្យបានច្រើន ការប្រុងប្រយ័ត្ន និងការឆាប់ដឹងអាចអនុញ្ញាតឱ្យយើង ដែលមិនប្រព្រឹត្តអំពើនេះជួយដោះស្រាយ ឬការពារនូវសោកនាដកម្មនៃការរំលោភបំពាន លើជនរងគ្រោះបន្ថែមទៀត ។

ការកើនឡើងជាញឹកញាប់នៃអំពើកាចសាហាវនេះ គឺជាអំពើបាបដ៏គួរឱ្យខ្លាច ដែលប្រហែលជាមិនបានប៉ះពាល់ដល់ជីវិតរបស់អ្នកផ្ទាល់នោះទេ ។ ប៉ុន្តែអំពើនេះបានរាលដាលគ្រប់គ្រាន់ល្មមនៅក្នុងពិភពលោក ដែលអំពើនេះអាចប៉ះពាល់ដល់នរណាម្នាក់ដែលអ្នកស្រឡាញ់ ។ ជាញឹកញាប់អំពើនេះបណ្តាលឱ្យមានការទទួលរងការឈឺចាប់យ៉ាងខ្លាំង---ដែលអាចយកឈ្នះបាន---ដែលខ្ញុំចង់និយាយនូវរបៀបដែលអាចទទួលបាននូវការព្យាបាល ។ ការនិយាយរបស់ខ្ញុំនឹងត្រូវបានសំរេចឡើងជាញឹកញាប់ ត្បិតគោលបំណងរបស់ខ្ញុំគឺដើម្បីជួយព្យាបាល និងមិនធ្វើឱ្យការចងចាំនៃការឈឺចាប់កាន់តែចុះដុនដាបឡើយ ។

*សិទ្ធិជ្រើសរើស*

សិទ្ធិជ្រើសរើសខាងសីលធម៌គឺជាវត្ថុធាតុយ៉ាងសំខាន់ នៅក្នុងផែនការនៃសុភមង្គលរបស់ព្រះវរបិតាដែលគង់

នៅស្ថានសួគ៌របស់យើង។ ទ្រង់ជ្រាបថាកូនចៅខាងវិញ្ញាណរបស់ទ្រង់មួយចំនួន នឹងប្រើប្រាស់សេរីភាពជ្រើសរើសមិនត្រឹមត្រូវ ដែលបង្កឱ្យមាននូវបញ្ហាដ៏ធ្ងន់ធ្ងរដល់អ្នកដទៃ។ ជនខ្លះថែមទាំងបំពានលើទំនុកចិត្តពិសិដ្ឋ ដូចជាឪពុក ឬសមាជិកគ្រួសារបំពានលើកុមារដែលបរិសុទ្ធ។ ដោយសារព្រះវរបិតាសួគ៌របស់យើងយុត្តិធម៌បំផុត នោះត្រូវតែមានមធ្យោបាយដើម្បីយកឈ្នះនូវផលមហន្តរាយ នៃការប្រើប្រាស់សេរីភាពជ្រើសរើសដែលធ្វើឱ្យខូចខាតបែបនោះ ទាំងជនដែលរងគ្រោះ និងអ្នកប្រព្រឹត្ត។ ការព្យាបាលដ៏មានសុវត្ថិភាពនោះ គឺមកតាមរយៈអំណាចនៃដង្វាយធួន នៃព្រះរាជបុត្រាស្ងួនភ្ងាររបស់ទ្រង់គឺព្រះយេស៊ូវគ្រីស្ទ ដើម្បីកែតំរូវអ្វីដែលអយុត្តិធម៌។ សេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ និងព្រះចេស្តារបស់ទ្រង់ដើម្បីព្យាបាលចំពោះការរំលោភបំពានដែលមានន័យថា ដើម្បីយកឈ្នះទៅលើផលដ៏គួរឱ្យខ្លាចនៃអំពើមិនសុចរិតរបស់អ្នកដទៃ។ នៅពេលដែលបានរួមផ្សំនឹងប្រែចិត្តទាំងស្រុង នោះដង្វាយធួនក៏នឹងជួយដល់អ្នកប្រព្រឹត្ត មាននូវវិធីដើម្បីជៀសវាងនូវទណ្ឌកម្ម ដែលព្រះអម្ចាស់បានដាក់បង្គាប់ចំពោះអំពើបែបនោះ។

*ចំពោះជនដែលរងគ្រោះ*

ខ្ញុំសូមថ្លែងថា ខ្ញុំដឹងថាជនរងគ្រោះអំពីរំលោភបំពានដ៏ធ្ងន់ធ្ងរ បានធ្វើដំណើរដ៏លំបាកប្រកបដោយជោគជ័យដើម្បីមានការព្យាបាលតាមរយៈអំណាចនៃដង្វាយធួន។ បន្ទាប់ពីកង្វល់ផ្ទាល់ខ្លួនរបស់នាង ត្រូវបានដោះស្រាយដោយសេចក្តីជំនឿរបស់នាង នៅក្នុងអំណាចព្យាបាលនៃដង្វាយធួន យុវនារីម្នាក់ដែលត្រូវបានរងការបំពានជាច្រើនដងដោយឪពុករបស់នាង បានស្នើឱ្យមានការសម្ភាសន៍ផ្សេងទៀត។ នាងបានត្រឡប់ទៅវិញជាមួយ នឹងប្តីប្រពន្ធដែលមានវ័យចំណាស់មួយគូ។ ខ្ញុំអាចយល់បានថានាងស្រឡាញ់ប្តីប្រពន្ធទាំងពីរនាក់នោះខ្លាំងណាស់។ ដោយទឹកមុខភ្លឺថ្លានៃសុភមង្គលរបស់នាង។ នាងបានចាប់ផ្តើមនិយាយថា: "អែលឌើរ ស្កត នេះគឺជាឪពុករបស់ខ្ញុំ។ ខ្ញុំស្រឡាញ់គាត់។ គាត់មានការព្រួយបារម្ភអំពីរឿងមួយ ដែលបានកើតឡើងកាលពីខ្ញុំនៅកុមារភាព។ បញ្ហាទាំងនោះ មិនមែនចោទជាបញ្ហាចំពោះខ្ញុំទៀតទេ។ តើលោកអាចជួយគាត់បានទេ?" វាគឺជាការបញ្ជាក់ដ៏អស្ចារ្យនៃសមត្ថភាព របស់ព្រះអង្គសង្គ្រោះដើម្បីធ្វើការព្យាបាល! នាងមិនទទួលរងការឈឺចាប់មកពីផលនៃការបំពានទៀតទេ ពីព្រោះនាងមានការយល់ដឹងគ្រប់គ្រាន់នៃដង្វាយធួនសេចក្តីជំនឿគ្រប់គ្រាន់ ហើយបានគោរពប្រតិបត្តិចំពោះច្បាប់របស់ទ្រង់។ នៅពេលដែលអ្នកសិក្សាដោយយកចិត្តទុកដាក់នូវដង្វាយធួន និងអនុវត្តសេចក្តីជំនឿរបស់អ្នកថា ព្រះយេស៊ូវគ្រីស្ទមានព្រះចេស្តាដើម្បីព្យាបាល អ្នកអាចទទួលបាននូវពរជ័យនៃការធ្វើឱ្យធូរស្រាលដូចគ្នា។ នៅអំឡុងការធ្វើដំណើរស្រាវជ្រាវរបស់អ្នក សូមទទួលយកការអញ្ជើញរបស់ទ្រង់ដើម្បីអនុញ្ញាតឱ្យទ្រង់ជួយសំរាលបន្ទុករបស់អ្នករហូតដល់អ្នកមានពេលវេលា និងកម្លាំងគ្រប់គ្រាន់ដើម្បីត្រូវបានព្យាបាល។

ដើម្បីស្វែងរកភាពធូរស្រាលពីផលនៃការរំលោភបំពាន វាជាជំនួយខ្លាំងណាស់ក្នុងការយល់ពីប្រភពរបស់វា។ សាតាំងគឺជាអ្នកនិពន្ធនៃលទ្ធផលហិនហោចនៃការរំលោភបំពាន។ វាមានសមត្ថភាពប្លែកពីធម្មតាក្នុងការដឹកនាំបុគ្គលទៅរកស្ថានភាពដែលគ្មានក្តីសង្ឃឹម ដែលគ្មានដំណោះស្រាយដើម្បីប្រឈមមុខដ៏ខ្លាំងក្លាចំពោះបញ្ហា។ យុទ្ធសាស្ត្ររបស់វាគឺដើម្បីបំបែកព្រលឹងនៃការឈឺចាប់ចេញពីការទទួលយកការព្យាបាលពីព្រះវរបិតាសួគ៌ប្រកបដោយសេចក្តីអណិតអាសូរ និងព្រះប្រោសលោះជាទីស្រឡាញ់។

បើអ្នកត្រូវបានរំលោភបំពាន នោះសាតាំងនឹងព្យាយាមបំភាន់អ្នកថា គ្មានដំណោះស្រាយនោះទេ។ ប៉ុន្តែវាដឹងយ៉ាងច្បាស់ថា គឺមានមធ្យោបាយដោះស្រាយ។ សាតាំងដឹងថាការព្យាបាលមានមកតាមរយៈសេចក្តីស្រឡាញ់ ដែលមិន

ចេះផ្លាស់ប្ដូរនៃព្រះវរបិតាសួគ៌សំរាប់កូនចៅរបស់ទ្រង់ម្នាក់ៗ។ វាក៏យល់ផងដែរថា អំណាចនៃការព្យាបាលគឺមាននៅក្នុងដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ។ ហេតុដូច្នោះហើយ យុទ្ធសាស្រ្តរបស់វាគឺដើម្បីធ្វើអ្វីៗដែលអាចធ្វើទៅបាន ដើម្បីបំបែកអ្នកពីព្រះវរបិតារបស់អ្នក និងព្រះរាជបុត្រារបស់ទ្រង់។ សូមកុំអនុញ្ញាតឱ្យសាតាំងបំភាន់អ្នកថា ទង្វើរបស់អ្នកមិនអាចជួយបានឡើយ។

សាតាំងប្រើប្រាស់ការរំលោភបំពានរបស់អ្នកដើម្បីធ្វើឱ្យអ្នកគ្មានទំនុកចិត្តលើខ្លួនឯង បំផ្លាញទំនុកចិត្តរបស់អ្នកលើសិទ្ធិអំណាច បង្កើតសេចក្ដីភ័យខ្លាច ហើយបង្កើតឱ្យមានអារម្មណ៏អស់សង្ឃឹម។ ការរំលោភបំពានអាចបំផ្លាញសមត្ថភាពរបស់អ្នកដើម្បីបង្កើតចំណងមិត្តភាពដ៏ល្អរបស់មនុស្ស។ អ្នកត្រូវតែមានសេចក្ដីជំនឿថា លទ្ធផលអវិជ្ជមានទាំងនេះអាចត្រូវបានដោះស្រាយបាន បើមិនដូច្នោះទេ វានឹងធ្វើឱ្យអ្នកមិនអាចជាសះស្បើយទាំងស្រុងបានទេ។ ខណៈពេលដែលផលទាំងនេះ មានឥទ្ធិពលដ៏ខ្លាំងក្លានៅក្នុងជីវិតរបស់អ្នក *នោះវាមិនបង្ហាញថាអ្នកជានរណាពិតប្រាកដទេ។*

សាតាំងនឹងព្យាយាមធ្វើឱ្យអ្នកប្រឆាំងនឹងព្រះវរបិតារបស់អ្នកដែលគង់នៅស្ថានសួគ៌ ជាមួយនឹងគំនិតដែលថា បើទ្រង់ ស្រឡាញ់អ្នក ទ្រង់នឹងការពារមិនឱ្យកើតមានសោកនាដកម្មឡើយ។ សូមកុំវាចវេរពីប្រភពនៃការព្យាបាលពិតប្រាកដ តាមរយៈល្បិចកលរបស់ស្ដេចនៃអំពើទុច្ចរិត និងការកុហកដ៏ទុច្ចរិតរបស់វាឡើយ។ សូមស្គាល់ថា បើអ្នកមានអារម្មណ៏ ដែលថាព្រះវរបិតារបស់អ្នកដែលគង់នៅស្ថានសួគ៌មិនស្រឡាញ់អ្នក នោះអ្នកកំពុងត្រូវបានបោកបញ្ឆោទដោយសាតាំងហើយ។ ទោះបីជាវាហាក់ដូចជាលំបាកដើម្បីធ្វើការអធិស្ឋានក្ដី សូមលុតជង្គង់ចុះហើយសុំដល់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ឱ្យប្រទានដល់អ្នកនូវសមត្ថភាពដើម្បីទុកចិត្តលើទ្រង់ ហើយដើម្បីទទួលបាននូវអារម្មណ៏នៃក្ដីស្រឡាញ់របស់ទ្រង់ចំពោះអ្នក។ សូមសួរដើម្បីដឹងថាព្រះរាជបុត្រារបស់ទ្រង់អាចព្យាបាលអ្នក តាមរយៈដង្វាយធួនប្រកបដោយសេចក្ដីមេត្តាករុណារបស់ទ្រង់។

គោលបំណងរបស់សាតាំងគឺថាកូនចៅរបស់ព្រះវរបិតាត្រូវបង្ខិតបង្ខំឱ្យគោរពតាម ថាគ្មានសេរីភាពជ្រើសរើសខាងសីលធមិនោះទេ ហើយហេតុដូច្នោះហើយគ្មានការរីកចំរើនខាងវិញ្ញាណនោះទេ។ ដើម្បីទទួលបានសេរីភាពជ្រើសរើសខាងសីលធម៌ ព្រះអម្ចាស់មិនបានបញ្ឈប់បុគ្គលទាំងឡាយ ពីការប្រើប្រាស់មិនត្រឹមត្រូវនៃសេរីភាពជ្រើសរើសនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ទ្រង់នឹងដាក់ទណ្ឌកម្មលើពួកគេចំពោះការប្រព្រឹត្តបែបនោះ លើកលែងតែមានការប្រែចិត្តទាំងស្រុង។ តាមរយៈព្រះវិញ្ញាណបរិសុទ្ធទ្រង់បញ្ជូនការបំផុសដ៏កក់ក្ដៅ ចំពោះអ្នកដែលធ្វើការរំលោភបំពាន ប៉ុន្តែជាញឹកញាប់ បំណងប្រាថ្នាអសីលធម៌របស់បុគ្គលនោះគឺមានអំណាចខ្លាំងណាស់ ដែលវារាំងស្ទះការដឹកនាំខាងវិញ្ញាណនោះ។ ហេតុនេះហើយទើបព្រះវរបិតាសួគ៌បានផ្ដល់ឱ្យនូវវិធី ដើម្បីព្យាបាលលទ្ធផលនៃទង្វើនោះ តាមរយៈកម្លាំង ការប្រើប្រាស់សិទ្ធិអំណាចខុស ឬសេចក្ដីភ័យខ្លាចដទៃទៀត ជាបណ្ដោះអាសន្នបានដកយកសេរីភាពជ្រើសរើសនៃអ្នកដែលបានរំលោភបំពាន។

ការចាប់ផ្ដើមការព្យាបាលតំរូវឱ្យមានសេចក្ដីជំនឿដូចជាកូនក្មេង លើការពិតដែលមិនអាចផ្លាស់ប្ដូរបានថា ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ស្រឡាញ់អ្នក ហើយបានផ្ដល់ឱ្យនូវវិធីដើម្បីព្យាបាល។ ព្រះរាជបុត្រាសំណប់របស់ទ្រង់ ព្រះយេស៊ូវ គ្រីស្ទ បានពលិកម្មជីវិតរបស់ទ្រង់ដើម្បីផ្ដល់ឱ្យនូវការព្យាបាលនោះ។ ប៉ុន្តែគ្មានដំណោះស្រាយដែលអស្ចារ្យ ឬថ្នាំធម្មតាដែលផ្ដល់ឱ្យនូវការព្យាបាល ឬថាបើមានផ្លូវងាយស្រួលដើម្បីធ្វើឱ្យជាសះស្បើយទាំងស្រុងនោះទេ។ ការព្យាបាល

តំរូវឱ្យមានសេចក្តីជំនឿដ៏ជ្រាលជ្រៅនៅលើព្រះយេស៊ូវគ្រីស្ទ ហើយសមត្ថភាពដើម្បីព្យាបាលដ៏គ្មានទីបញ្ចប់របស់ទ្រង់។ វាគឺជាឬសគល់នៅក្នុងការយល់ដឹងនៃគោលលទ្ធិ និងការប្តេជ្ញាចិត្តដ៏អង់អាចដើម្បីធ្វើតាមវា។

ការព្យាបាលអាចចាប់ផ្តើមជាមួយនឹងប៊ីស្សពដែលចេះគិតវែងឆ្ងាយ ឬប្រធានស្តេក ឬអ្នកប្រឹក្សាជំនាញដែលវាងវៃ។ បើជើងរបស់អ្នកបាក់ អ្នកនឹងមិនសំរេចចិត្តថានឹងតជើងរបស់អ្នកដោយខ្លួនឯងនោះទេ។ ការរំលោភបំពានដ៏ធ្ងន់ធ្ងរអាចទទួលពិគ្រោះពីអ្នកជំនាញផងដែរ។ មានមធ្យោបាយជាច្រើនដើម្បីចាប់ផ្តើមព្យាបាល ប៉ុន្តែសូមចងចាំថាការព្យាបាលទាំងស្រុងគឺមានតាមរយៈព្រះអង្គសង្គ្រោះ ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ជាចៅហ្វាយ និងជាព្រះប្រោសលោះរបស់យើង។ មានសេចក្តីជំនឿដែលមានការគាំទ្រពីដង្វាយធួនដ៏ឥតខ្ចោះ អស់កល្បជានិច្ច ជានិរន្តរ៍របស់ទ្រង់អាចព្យាបាលការឈឺចាប់របស់អ្នកពីផលនៃការរំលោភបំពាន។

តាមដែលអាចធ្វើទៅបានចំពោះអ្នកឥឡូវនេះ នៅពេលដែលការព្យាបាលដែលអ្នកអាចទទួលពីព្រះអង្គសង្គ្រោះនឹងអនុញ្ញាតឱ្យអ្នកអភ័យទោសយ៉ាងពិតប្រាកដដល់អ្នកដែលរំលោភបំពាន ហើយថែមទាំងមានអារម្មណ៏សោកស្តាយចំពោះគាត់ ឬនាងដែលបានប្រព្រឹត្ត។ នៅពេលអ្នកអាចអភ័យទោសដល់អ្នកដែលទាស់ចិត្តអ្នក នោះការឈឺចាប់ និងការឈឺចិត្តដែលសាតាំងចង់ដាក់ឱ្យមាននៅក្នុងជីវិតរបស់អ្នក ដោយការលើកទឹកចិត្តអ្នកឱ្យស្អប់ ដល់អ្នកធ្វើការរំលោភបំពាន់នឹងបានធូរស្រាល។ ជាលទ្ធផលអ្នកនឹងរីករាយនូវសេចក្តីសុខសាន្តដ៏មហិមា។ ខណៈដែលជាផ្នែកដ៏សំខាន់មួយនៃការព្យាបាល បើគំនិតនៃការអភ័យទោសបណ្តាលឱ្យអ្នកកាន់តែឈឺចាប់ សូមទុកជំហ៊ាននោះនៅមួយឡែកសិន រហូតដល់អ្នកកាន់តែមានបទពិសោធន៏ជាមួយនឹង ព្រះអង្គសង្គ្រោះនៅក្នុងជីវិតរបស់អ្នកផ្ទាល់។ 1

បើអ្នកទើបតែបានប្រព្រឹត្តអំពើរំលោភបំពានក្នុងពេលថ្មីៗ ឬពីអតីតកាល សូមមានសេចក្តីក្លាហានដើម្បីស្វែងរកជំនួយ។ អ្នកប្រហែលជាត្រូវបានគំរាមគំហែងយ៉ាងខ្លាំង ឬបណ្តាលឱ្យមានសេចក្តីភ័យខ្លាច ដើម្បីអ្នកមិនបើកបង្ហាញនូវការរំលោភបំពាននោះ។ សូមមានសេចក្តីក្លាហានដើម្បីបង្ហាញវាឥឡូវនេះ។ សូមស្វែងរកជំនួយពីនរណាម្នាក់ដែលអ្នកអាចទុកចិត្តបាន។ ប៊ីស្សព ឬប្រធានស្តេករបស់អ្នកអាចផ្តល់ឱ្យអ្នកនូវពាក្យប្រឹក្សាដ៏មានតម្លៃ ហើយជួយអ្នកជាមួយនឹងសិទ្ធិ អំណាចស៊ីវិល។ សូមពន្យល់ពីរបៀបដែលអ្នកបានធ្វើការរំលោភបំពាន ហើយបញ្ជាក់ថាតើនរណាបានទទួលរងការរំលោភបំពាន។ ចូរស្វែងរកការការពារ។ សកម្មភាពរបស់អ្នកអាចជួយអ្នកដទៃមិនឱ្យក្លាយជាជនរងគ្រោះដែលមិនដឹងខ្លួន ដោយផលនៃការទទួលរងការឈឺចាប់។ សូមស្វែងរកជំនួយឥឡូវនេះ។ សូមកុំខ្លាច---ត្បិតសេចក្តីភ័យខ្លាចគឺជាឧបករណ៏ដែលសាតាំងនឹងប្រើដើម្បីទុកឱ្យអ្នកទទួលនូវការឈឺចាប់។ ព្រះអម្ចាស់នឹងជួយអ្នក ប៉ុន្តែអ្នកត្រូវតែឈោងទៅរកជំនួយនោះ។

សូមកុំបាក់ទឹកចិត្ត បើប៊ីស្សពចាប់ផ្តើមស្ទាក់ស្ទើរ នៅពេលដែលអ្នកប្រាប់អំពីអ្នកធ្វើការរំលោភបំពាន។ អ្នកដែលជញ្ជក់ឈាមគឺមានជំនាញក្នុងការបង្កើតរូបរាងជាសាធារណៈថា ជាអ្នកស្មោះត្រង់ ដើម្បីលាក់បាំងនូវទង្វើដ៏គួរឱ្យស្អប់របស់ពួកគេ។ សូមអធិស្ឋានដើម្បីត្រូវបានដឹកនាំនៅក្នុងកិច្ចខិតខំរបស់អ្នក ដើម្បីទទួលបានជំនួយ។ ជំនួយនោះនឹងមក ដល់។ ចូរមានទំនុកចិត្តថាការជំនុំជំរះដ៏ឥតខ្ចោះថាព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ជាមួយនឹងចំណេះដឹងដ៏ឥតខ្ចោះនៃភាពលំអិតនឹងទុកឱ្យអ្នកដែលធ្វើការរំលោភបំពានទទួលខុសត្រូវលើអ្វីៗដែលជាទង្វើទុច្ចរិត។ នៅពេលខ្លះទ្រង់នឹងអនុវត្តនូវតំរូវការនៃសេចក្តីយុត្តិធម៌ លើកលែងតែមានការប្រែចិត្តទាំងស្រុង។ កង្វល់របស់អ្នកជាមួយនឹងសេចក្តីត្រូវការសំរាប់សេចក្តីយុត្តិធម៌ វាគ្រាន់តែបង្អាក់នូវការព្យាបាលរបស់អ្នកប៉ុណ្ណោះ ហើយអនុញ្ញាតឱ្យអ្នកប្រព្រឹត្តបន្តការគ្រប់គ្រង

ហួសហេតុរបស់គាត់។ ហេតុដូច្នេះហើយអ្នកគួរតែទុកទណ្ឌកម្មឱ្យមាន លើទង្វើកំណាចនៃការរំលោភបំពានចំពោះសិទ្ធិអំណាចស៊ីវិល និងសិទ្ធិអំណាចនៃសាសនាចក្រ។

*ចំពោះជនដែលប្រព្រឹត្ត*

ឥឡូវនេះចំពោះអ្នកដែលប្រព្រឹត្ត ដែលបានធ្វើឱ្យជីវិតរបស់អ្នកដទៃបានវិនាស ដោយសារតែការរំលោភបំពាន : សូមដឹងថាអ្នកត្រូវការជំនួយលើការញៀនរបស់អ្នក ឬវានឹងបំផ្លាញខ្លួនរបស់អ្នក។ អ្នកនឹងមិនយកឈ្នះលើវា ដោយខ្លួនឯងឡើយ។ អ្នកត្រូវការជំនួយពីអ្នកជំនាញយ៉ាងប្រាកដ។ ខ្ញុំសូមអង្វរដល់អ្នកសូមឱ្យស្វែងរកជំនួយសង្គ្រោះ *ឥឡូវនេះ*។ អ្នកប្រហែលជាបានបំភាន់ដល់ខ្លួនឯងនៅក្នុងរឿងក្លែងក្លាយ សុវត្ថិភាពបណ្ដោះអាសន្ន ដែលអ្នកបានលាក់បាំងយ៉ាងមានជោគជ័យនូវការរំលងរបស់អ្នកពីសិទ្ធិអំណាចស៊ីវិល ឬសិទ្ធិអំណាចរបស់សាសនាចក្រ។ ប៉ុន្តែសូមដឹងថាព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ គឺពិតជាបានជ្រាបដឹងពីអំពើបាបរបស់អ្នក ។ ទ្រង់បានព្រមានថា៖ "បើអ្នកណាធ្វើឱ្យកូនតូចណាមួយនេះ... រវាចិត្តចេញនោះស៊ូឱ្យគេយកថ្មត្បាល់កិនយ៉ាងធំចងក អ្នកនោះ ហើយពន្លង់ទៅក្នុងសមុទ្រទីជ្រៅវិញ"។2 សូមដឹងថាពេលខ្លះ វិធីខ្លះ សកម្មភាពហួសហេតុរបស់អ្នកនឹងត្រូវ ប្រកាសជាសាធារណៈ។ សាតាំងនឹងធ្វើឱ្យប្រាកដថាកិច្ចការទាំងនោះកើតឡើងពិតប្រាកដមែន។

ធ្វើឱ្យជីវិតរបស់អ្នកសាមញ្ញដោយការបោះជំហាន *ឥឡូវនេះ* ដើម្បីសំអាតព្រលឹងរបស់អ្នកចេញពីអំពើបាបបែបនោះ និងដោះស្រាយនូវទណ្ឌកម្មដែលអំពើបាបទាំងនោះបង្កើតឡើង។ សូមបង្ហាញបំណងប្រាថ្នារបស់អ្នកដើម្បីព្យាបាលនូវភាពតានតឹងដែលអ្នកបានបង្កឱ្យអ្នកដទៃ។ សូមប្រាប់ទៅប៊ីស្សពរបស់អ្នក ឬប្រធានស្តេក។ ទង្វើដ៏ធ្ងន់ធ្ងររបស់អ្នកអាច តំរូវឱ្យអ្នកប្រឈមមុខនឹងការដាក់វិន័យស៊ីវិល និងដាក់វិន័យរបស់សាសនាចក្រ។ ប៉ុន្តែការប្រែចិត្តទាំងស្រុង នឹងនាំមកនូវការធូរស្បើយដ៏ផ្អែមល្ហែមនៃការអភ័យទោស សេចក្តីសុខសាន្តនៃមនៈសិការ និងការផ្លាស់ថ្មីនៃជីវិត។ វាក៏នឹងនាំមកនូវភាពធូរស្រាល ចំពោះអ្នកដែលត្រូវបានរំលោភបំពាន និងក្រុមគ្រួសាររបស់ពួកគេ។ អ្នកនឹងមានសេរីភាពពីទម្ងន់នៃវិប្បដិសារី និងការបណ្តាលឱ្យមានគំនិត ដែលបណ្តាលឱ្យអ្វីដែលអ្នកបានបង្ក នៅក្នុងការសោកសៅ និងមានភាពតានតឹងនៅក្នុងជីវិតរបស់អ្នកដទៃ។ សូមកត់សំគាល់ថា វាងាយស្រួលជាងដើម្បីប្រែចិត្តនៅក្នុងជីវិតនេះ ជាជាងប្រែចិត្តនៅជីវិតបន្ទាប់ ដូច្នេះសូមប្រែចិត្តឥឡូវនេះ។ អ្នកនឹងទទួលបានជំនួយនៅពេលអ្នកសំរេចចិត្តថាបោះចោលការញៀនរបស់អ្នក តាមរយៈការប្រែចិត្ត និងគាំទ្រដល់អ្នកដទៃ។ សូមមានអំណរគុណដែលអ្នកមិនបានរស់នៅក្នុងសម័យបុរាណនៅពេលដែលពួកអ្នករំលោភបំពានត្រូវចោលថ្មដល់ស្លាប់ ដោយគ្មានឱកាសដើម្បីប្រែចិត្តឡើយ។3

*ចំពោះឪពុកម្តាយ*

ឪពុកម្តាយទាំងឡាយ តាមមធ្យោបាយដ៏សមរម្យ និងងាយដឹងសូមបង្រៀនកូនចៅរបស់អ្នកពីគ្រោះថ្នាក់ដែលអាចកើតមាននៃការរំលោភបំពាន ហើយបង្រៀនរបៀបដើម្បីជៀសវាងវា។ សូមប្រុងប្រយ័ត្នចំពោះសញ្ញាព្រមានដូចជា ការផ្លាស់ប្តូរភ្លាមៗនៅក្នុងឥរិយាបទរបស់កុមារ ដែលសញ្ញានៃបញ្ហា។ សូមប្រយ័ត្នប្រយែងចំពោះអារម្មណ៍មួរម៉ៅរបស់កូនអ្នក ហើយស្វែងយល់នូវការចាប់ផ្តើមនៃអារម្មណ៍របស់ពួកគេ។

*ចំពោះចៅក្រមក្នុងអ៊ីស្រាអែល*

ចំពោះអ្នកដែលកាន់កូនសោចៅក្រមនៃអ៊ីស្រាអែល សូមបញ្ជាក់ដោយយកចិត្តទុកដាក់ថា បុគ្គលម្នាក់ៗដែលកំពុងទទួលរងការឈឺចាប់ដោយការរំលោភបំពានបានទទួលជំនួយសមរម្យ។ សៀវភៅណែនាំរបស់សាសនាចក្រ និងទូរស័ព្ទជំនួយដែលបានសរសេរនៅទីនោះគឺជាធនធានដ៏មានតម្លៃ ដើម្បីដឹកនាំសកម្មភាពស្របច្បាប់របស់សាសនាចក្រ ហើយធ្វើការសំរបសំរួលជាមួយនឹងអជ្ញាធរស៊ីវិល។4 សូមគ្រប់គ្រងការចូលរួមដោយយកចិត្ត ទុកដាក់ចំពោះគ្រប់បុគ្គលដែលអាចមានការអាក់អន់ចិត្តមកពីអតីតកាល។ សូមដឹងថាអ្នកប្រព្រឹត្តប្រហែលជានឹងមិនសារភាពនូវសកម្មភាពគ្មានគុណធម៌របស់គាត់ឡើយ។ សូមស្វែងរកនូវការណែនាំពីព្រះវិញ្ញាណ នៅពេលអ្នកមានអារម្មណ៍ថាអ្វីមួយមិនប្រក្រតី។ សូមរួមបញ្ចូលទាំងជំនួយរបស់ពួកអ្នកដឹកនាំវួដ និងស្តេកដើម្បីជៀសវាងពីគ្រោះថ្នាក់ ដែលអាចកើតមានជាយថាហេតុ។

ខ្ញុំសូមអធិស្ឋានថាអ្នក ដែលជាអ្នកដែលត្រូវបានរំលោភបំពាន ឬអ្នកដែលបង្កឱ្យមានការរំលោភបំពាន សូមធ្វើសកម្មភាពឥឡូវនេះដើម្បីធ្វើឱ្យខ្លួនរបស់អ្នកមាននូវអំណាចនៃការព្យាបាល នៃដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា សេចក្តីជំនឿ និងការប្រណិបត្តិរបស់អ្នកនឹងបញ្ជាក់ថា ទ្រង់នឹងជួយអ្នក។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. សម្ភារៈទាំងនេះអាចជួយធ្វើការសោកដនាកម្មនៃការរំលោភបំពានបានធូរស្រាលៈ សូមមើល ហ្គរដុន ប៊ី ហ៊ិងគ្លី "Save the Children" *Ensign* ខែវិច្ឆិកា ឆ្នាំ 1994, 52--54។ ជែមស៍ អ៊ី ហ្វោស្ត "The Atonement: Our Greatest Hope" *លីអាហូណា* ខែមករា ឆ្នាំ 2002 ទំព័រ 19--22 ដាល្លិន អេក អូក "He Heals the Heavy Laden" *លីអាហូណា* ខែវិច្ឆិកា ឆ្នាំ 2006 ទំព័រ 6--9។ រីឆាដ ជេ ស្កត "Healing the Tragic Scars of Abuse" *Ensign* ខែឧសភា ឆ្នាំ 1992, 31--33 "Trust in the Lord" *Ensign* ខែវិច្ឆិកា ឆ្នាំ 1995, 16--18 "Peace of Conscience, Peace of Mind" *Ensign* ខែវិច្ឆិកា ឆ្នាំ 2004, 15--18 រីឆាដ ជេ ស្កត "The Atonement Can Secure Your Peace and Happiness" *លីអាហូណា* ខែវិច្ឆិកា ឆ្នាំ 2006, 40--42 ជែហ្វ្រី អរ៍ ហូឡិន "Broken Things to Mend" *លីអាហូណា* ខែឧសភា ឆ្នាំ 2006, 69--71 "A Conversation on Spouse Abuse" *Ensign* ខែតុលា ឆ្នាំ 1999, 22--27 "The Wrongful Road of Abuse" ជំពូកទី 28 នៅក្នុង *Teachings of Presidents of the Church: Joseph F. Smith* (វគ្គសិក្សាបព្វជិតភាពមិលគីស្សាដែក និងសមាគមសង្គ្រោះ) 249--55 គ. និង ស. 121:34--46។

2. ម៉ាថាយ 18:6។

3. សូមមើល ចោទិយកថា 22:25--27។

4. សូមមើល Church Handbook of Instructions, Book 1, (2006), 107--8, 110, 120, 122, 147, 186។